# សេចក្តីថ្លែងការព័ត៌មាន

## មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បញ្ចប់បេសកកម្មមកកម្ពុជា

## ភ្នំពេញ, ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៧

បេសកកម្មមួយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ មកពីទីក្រុងវ៉ាស៊ីនតោន ឌីស៊ី បានធ្វើទស្សនៈកិច្ចនៅកម្ពុជា ពីថ្ងៃទី 14 ដល់ 21 ខែ កុម្ភៈ ឆ្នាំ 2007 ដើម្បីជួបពិភាក្សាជាមួយ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី និង មន្ត្រីជាន់ខ្ពស់នានា នៃរាជរដ្ឋាភិបាលកម្ពុជា អំពី គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង រចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ។ បេសកកម្ម ក៏បានជួបជាមួយអ្នកតំណាងនានាពី សហគមពាណិជ្ជកម្ម និង ដៃគូអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលដែរ ។

### ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច

ការអនុវត្តន៍ម៉ាក្រូសេដ្ឋកិច្ច ក្នុងឆ្នាំ 2006 បានប្រសើរជាទីបំផុត ។ កំណើននៃផលទុនជាតិ (គិតជាតំលៃថេរ) ចំនួន 10½ ភាគរយ បាននាំមុខដោយសកម្មភាពដ៏ខ្លាំងក្លានៅតែបន្ត ក្នុងវិស័យទេសចរណ៍ នាំចេញសំលៀកបំពាក់សំណង់ នៅពេលដែលផលិតផលកសិកម្មបានរីកដុលដាល ។ កំណើនប្រមាណ ៩ភាគរយ ត្រូវបានសង្ឃឹមទុកនៅឆ្នាំ 2007 នេះ ។

អតិផរណាថយចុះមកត្រឹម 2¾ ភាគរយ នៅចុងឆ្នាំ 2006 ដែលឆ្លុះបញ្ចាំងពីការប្រមូលផលបានប្រសើរ និង ការថយចុះនៃតំលៃប្រេងនៅទីផ្សារពិភពលោក ។ អតិផរណាត្រូវសង្ឃឹមថា នឹងនៅតែទាប បន្តទៀត ក្នុងឆ្នាំ 2007 ។ អោនភាពគណនេយ្យចរន្តក្រៅប្រទេស (ដោយមិនរាប់បញ្ចូលជំនួយឥតសំណង) រួមតូច មកត្រឹម 7¾ ភាគរយនៃផលទុនជាតិ ។ កំនើនយ៉ាងខ្លាំងនៃវិនិយោគឯកជនផ្ទាល់ បានរួមចំណែកអោយមានការកើនឡើងនៃទុនបំរុងអន្តរជាតិ ដល់ទៅ $ 1.1 ពាន់លាន នៅដំណាច់ឆ្នាំ 2006 ។

ចំណូលរបស់រដ្ឋាភិបាលកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ 2006 ឆ្លុះបញ្ចាំងសកម្មភាពសេដ្ឋកិច្ចដ៏ខ្លាំងក្លា និង ការកែលំអការខិតខំប្រឹងប្រែងនៃការប្រមូលចំណូល ទោះបីជាអត្រាចំណូលពីពន្ធធៀបនឹងផលទុនជាតិ (Tax revenue-to-GDP ratio)

នៅតែស្ថិតនៅត្រឹម 8 ភាគរយ ។ ចំណាយត្រូវបានរិតត្បិត ជាពិសេសចំណាយមូលធន ចំនែកឯបំណុលចំណាយដែលជំពាក់បានថយចុះ ។ អោនភាពថវិកាទូទៅថយចុះមកត្រឹម 1½ ភាគរយ នៃផលទុនជាតិ ។

ការពិភាក្សាអំពីនយោបាយសារពើពន្ធ បានគូសបញ្ជាក់អំពីការបង្កើនចំណាយសំរាប់ការកាត់បន្ថយភាពក្រីក្រ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធសមស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ។ ត្រូវបានយល់ស្របគ្នាថា ការធ្វើហិរញ្ញប្បទាននៃចំណាយនេះ គួរត្រូវបានមកពីការខិតខំដោយចិរភាព ក្នុងការបង្កើនការប្រមូលចំណូល ហើយ គោលដៅនានានៃថវិកាក្នុងឆ្នាំ 2007 អាចនឹងត្រូវសំរេចបានលើស តាមរយៈវិធានការបង្កំប្រមូលចំណូលខ្លាំងក្លាជាងមុន ។

វិស័យធនាគារ បានរីកដុះដាលគួរអោយគត់សំគាល់ ក្នុងឆ្នាំ 2006 ដោយមានការកើនឡើងខ្លាំងទាំងប្រាក់បញ្ញើរ និង ប្រាក់កម្ចី ។ បេសកកម្មបានយល់ឃើញថា នេះគឺជាការកើនឡើងនៃការជឿទុកចិត្តចំពោះប្រព័ន្ធហិរញ្ញវត្ថុ ដែលកំពុងចាប់កំណើត របស់ប្រទេសកម្ពុជា ហើយបេសកកម្មក៏ស្វាគមន៍ចំពោះ ការប្តេជ្ញាចិត្តនានា ដើម្បីបន្តការ សង្កេតមើលការអភិវឌ្ឍន៍នេះយ៉ាងជិតស្និត ។

**ការកែទំរង់រចនាសម្ព័ន្ធនានា**

ការកែទំរង់រចនាសម្ព័ន្ធ គឺជាគន្លឹះដើម្បីកំណើនមានចិរភាព និង ការកាត់បន្ថយភាពក្រីក្រ ។ ការរីកចំរើន ក្នុងកម្មវិធីកំណែទំរង់នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវសំរេចបាន ហើយបេសកកម្មស្វាគមន៍ផែនការនានា ដើម្បីពង្រឹង ការគ្រប់គ្រងសាច់ប្រាក់ និង នីតិវិធីនានាសំរាប់ការអនុវត្តន៍ថវិកា ។ ជាពិសេសប្រព័ន្ធគណនេយ្យថ្មី របស់រតនាគារជាតិ នឹងអនុញ្ញាតអោយមានការរាយការណ៍បានប្រសើរជាងមុន អំពីចំណាយដើម្បីកាត់បន្ថយភាពក្រីក្រ ។ ការពង្រឹងជាបន្ត នូវច្បាប់នានានិងការត្រួតពិនិត្យ លើវិស័យហិរញ្ញវត្ថុ ត្រូវបានសង្ឃឹមថានឹង ពង្រឹងជាបន្ថែម ហើយគាំពារ ភាពរឹងមាំរបស់ប្រព័ន្ធហិរញ្ញវត្ថុនេះ ។

**ការកាត់បំណុលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ**

ប្រទេសកម្ពុជាទទួលបានការកាត់បំណុលចំនួនប្រហែល US$ 82 លាន ក្នុងខែមករា ឆ្នាំ 2006 នៅក្រោម កិច្ចផ្តួចផ្តើមកាត់បំណុលពហុភាគី (MDRI) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ បេសកកម្មបានពិភាក្សាអំពីការ អនុវត្តន៍គំរោងធារាសាស្ត្រជនបទថ្មីៗមួយចំនួន របស់រាជរដ្ឋាភិបាល និង ស្វាគមន៍ដំណឹងដែលថា ការដេញថ្លៃជា សាធារណៈ នឹងត្រូវចាប់ផ្តើមក្នុងពេលឆាប់ៗនេះ ។

## ស្ថានភាពរបស់កម្មវិធី PRGF

បេសកកម្មបានទទួលដំណឹងថា ការចរចាររវាង កម្ពុជា និង ម្ចាស់បំណុលជាផ្លូវការនានារបស់កម្ពុជា លើបំណុលចាស់នៅតែមិនទាន់បានសំរេចនៅឡើយ ។ នេះធ្វើអោយមានការពន្យារនៃការគិតគូរ ដោយគណៈកម្មការប្រតិបត្តិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ អំពីសំណើរបស់រដ្ឋាភិបាលសំរាប់ការឧបត្ថម្ភជាហិរញ្ញវត្ថុ ក្រោមកម្មវិធីនៃការលូតលាស់ និង កាត់បន្ថយភាពក្រីក្រ[1] ។ ក្នុងករណីនេះ បេសកកម្មយល់ព្រមតាមសំណូមពររបស់រដ្ឋាភិបាល ដែលសុំអោយថែរក្សារទុក នូវការពិគ្រោះពិភាក្សាគោលនយោបាយយ៉ាងខ្លាំងក្លា លើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង រចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ដែលមានទិសដៅគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏ជាតិ។ ការពិគ្រោះពិភាក្សានេះ ត្រូវផ្អែកទៅលើការថែរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ចិរភាពនិងការពង្រឹងការខំប្រឹងប្រែងដើម្បីកែលំអ កំរិតនិងរចនាសម្ព័ន្ធ នៃចំណូលនិងចំណាយរបស់រដ្ឋាភិបាល និង ការកែទំរង់រចនាសម្ព័ន្ធ នៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិស័យហិរញ្ញវត្ថុ ។

---

[1] កម្មវិធីសំរាប់ការលូតលាស់ និង ការកាត់បន្ថយភាពក្រីក្រ (PRGF) គឺជាកម្ចីសម្បទានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ សំរាប់ប្រទេសនានាដែលមានចំណូលតិច ។ គោលការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ គឺមិនអនុញ្ញាតផ្តល់កម្ចីអោយប្រទេសសមាជិកណាមួយ នៅពេលដែលមានការជំពាក់បំណុលចាស់ដែលមិនទាន់ដោះស្រាយជាមួយម្ចាស់បំណុលផ្លូវការ ។